ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# សកម្មភាព និងលទ្ធផល
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំនព្វមាស ឆ្នាំ២០២៥

## របស់
## មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## រាជធានីភ្នំពេញ

# របាយការណ៍
# សកម្មភាព និងលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែឧសភា ឆ្នាំ២០២៥
# របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ

**១. ស្ថានភាពមន្ត្រី** (ឧបសម្ព័ន្ធ ១)

មន្ត្រីរាជការកំពុងបម្រើការងារក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ មានចំនួនសរុប ១៥៥នាក់(ស្រី៣០នាក់) ក្នុងនោះមន្ត្រីក្របខ័ណ្ឌ"ក" ចំនួន៨២នាក់(ស្ត្រី១០នាក់) ក្របខ័ណ្ឌ"ខ" ចំនួន៤៤នាក់(ស្ត្រី ១៤នាក់) ក្របខ័ណ្ឌ"គ" ចំនួន២៩នាក់(ស្ត្រី៦នាក់) និងមន្ត្រីជាប់កិច្ចសន្យាសរុបចំនួន០៨នាក់(ស្រី០២នាក់)។ នៅក្នុងខែឧសភា នេះដែរ មានមន្ត្រីបានចូលនិវត្តន៍ ចំនួន ២នាក់(ស្ត្រី១នាក់) មន្ត្រីបានផ្ទេរក្របខ័ណ្ឌទៅបម្រើការងារនៅអង្គភាពផ្សេង ចំនួន១នាក់ មន្ត្រីបានផ្លាស់ចូលមកពីអង្គភាពផ្សេង ចំនួន១នាក់ និងមន្ត្រីចំនួន១នាក់ បានទទួលមរណភាព។

**២. សកម្មភាព និងលទ្ធផលការងារ**

**ក. ការងារបង្កបង្កើនផល** (ឧបសម្ព័ន្ធ ២)

**ក.១.ស្រូវរដូវប្រាំង ឆ្នាំ២០២៤-២០២៥** (ចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០២៤ និងបញ្ចប់ត្រឹមខែមេសា ឆ្នាំ២០២៥)

- ផែនការ ៖ ២៨០ហ.ត
- ផ្ទៃដីភ្ជួររាស់សរុប ៖ ៣៤០ហ.ត « ភ្ជួររាស់ដោយគ្រឿងយន្ត »
- ផ្ទៃដីដាំដុះសរុប ៖ ៣៤០ហ.ត =១២១,៤៣%នៃផែនការ(ស្រូវពង្រោះ)
- ការប្រមូលផល ៖
  - ផ្ទៃដីប្រមូលផល : ៣៤០ហ.ត (បញ្ចប់ការប្រមូលផល)
  - បរិមាណផល : ១ ២១៧តោន
  - ទិន្នផល : ៣,៥៨តោន/ហ.ត។

**ក.២.ដំណាំរដូវប្រាំង ឆ្នាំ២០២៤-២០២៥** (ចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០២៤ និងបញ្ចប់ត្រឹមខែមេសា ឆ្នាំ២០២៥)

- ដំណាំសាកវប្បកម្ម ៖ អនុវត្តបានសរុប: ១១០ហ.ត = ៩១,៦៦% នៃផែនការ ១២០ហ.ត
  - ផ្ទៃដីប្រមូលផល : ១១០ហ.ត (បញ្ចប់ការប្រមូលផល)
  - បរិមាណផល : ៩០៨តោន
  - ទិន្នផល : ៨,២៥តោន/ហ.ត។
- ដំណាំឧស្សាហកម្ម ៖ អនុវត្តបានសរុប: ៣០ហ.ត = ១០០% នៃផែនការ ៣០ហ.ត
  - ផ្ទៃដីប្រមូលផល : ៣០ហ.ត (បញ្ចប់ការប្រមូលផល)
  - បរិមាណផល : ៣៣០,៥០តោន
  - ទិន្នផល : ១១តោន/ហ.ត។

**ក.៣.ស្រូវរដូវវស្សា ឆ្នាំ២០២៥** (ចាប់ផ្តើមពីខែឧសភា ឆ្នាំ២០២៥)

- ផែនការ ៖ ៤ ២០០ហ.ត
- ផ្ទៃដីភ្ជួររាស់សរុប ៖ ៤ ៣២០ហ.ត « ភ្ជួររាស់ដោយគ្រឿងយន្ត »
- ផ្ទៃដីសាប សរុប ៖ ២១ហ.ត
- ផ្ទៃដីដាំដុះសរុប ៖ ៤ ៣២០ហ.ត =១០២,៨៥%នៃផែនការ
  - សន្ទូង ១៤៥ហ.ត
  - ពង្រោះ ៤ ១៧៥ហ.ត

- ការប្រមូលផល ៖
  - ផ្ទៃដីប្រមូលផល : ៧៩៨ហ.ត
  - បរិមាណផល : ២ ៣៣១តោន
  - ទិន្នផល : ២,៩៣តោន/ហ.ត។

**ក.៤.ដំណាំរដូវវស្សា ឆ្នាំ២០២៥** (ចាប់ផ្តើមពីខែឧសភា ឆ្នាំ២០២៥)

- ដំណាំសាកវប្បកម្ម ៖ អនុវត្តបានសរុប: ៩៥ហ.ត = ៧៩,១០% នៃផែនការ ១២០ហ.ត
- ដំណាំឧស្សាហកម្ម ៖ អនុវត្តបានសរុប: ៤០ហ.ត = ១០០% នៃផែនការ ៤០ហ.ត

**ក.៥. ផលប៉ះពាល់ដោយការរាំងស្ងួត និងការអន្តរាគមន៍សង្គ្រោះ**

- នៅក្នុងខែមករា មានការរាំងស្ងួតបានបង្កផលប៉ះពាល់ដល់ដំណាំស្រូវរដូវប្រាំងសរុបចំនួន២១,៥០ហ.ត នៅ
- សង្កាត់បឹងធំ ខណ្ឌកំបូល(ភូមិក្អែក ៨ហ.ត ភូមិដូនកុក ៣.៥ហ.ត និងភូមិខ្ចៅ ១០ហ.ត) តែមិនមានការខូចខាតទេ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ បានសហការជាមួយមន្ទីរធនធានទឹករាជធានីភ្នំពេញ និងអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋានជួយអន្តរាគមន៍បូមទឹកជួយសង្គ្រោះទាន់ពេលវេលា។
- នៅក្នុងដើមខែសីហា មានការរាំងស្ងួត ដែលបណ្តាលមានការប៉ះពាល់ផ្ទៃដីស្រូវសន្ទូង និងពង្រោះសរុបចំនួន ២៩៤ហ.ត នៅក្នុងសង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ តែមិនមានការខូចខាតទេ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ សហការជាមួយមន្ទីរធនធានទឹករាជធានីភ្នំពេញ និងអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋានអន្តរាគមន៍បូមទឹកសង្គ្រោះទាន់ពេលវេលា។

**ក.៦.ការងារផ្សព្វផ្សាយ ណែនាំបច្ចេកទេស និងការចូលរួមវគ្គបណ្តុះបណ្តាល និងពិធីផ្សេងៗ**

- ថ្នាក់ដឹកនាំមន្ទីរ លោកនាយខណ្ឌ និងមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើភ្នំពេញចូលរួមពិធីរុក្ខទិវាថ្នាក់ជាតិ ០៩ កក្កដា ឆ្នាំ២០២៥ ប្រារព្ធនៅភូមិកសិដ្ឋាន ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម។
- ថ្នាក់ដឹកនាំមន្ទីរ និងប្រធានអង្គភាព/ការិយាល័យជំនាញចូលរួមកិច្ចប្រជុំពិនិត្យផ្ទៀងផ្ទាត់លើរបាយការណ៍វិភាគទិន្នន័យចុងក្រោយនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤។
- ថ្នាក់ដឹកនាំមន្ទីរ និងប្រធានការិយាល័យនីតិកម្មកសិកម្ម ចូលរួមកិច្ចប្រជុំ ពិភាក្សាស្តីពីការពង្រឹងគុណភាពជីកសិកម្ម និងថ្នាំកសិកម្មនៅអគ្គនាយកដ្ឋានកសិកម្ម។
- ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក ចូលរួមសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤-២០២៨។
- ការិយាល័យផែនការ គណនេយ្យ ចូលរួមកិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេស ស្តីពីការប្រមូលធាតុចូលសម្រាប់រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ របស់រដ្ឋបាលរាជធានីភ្នំពេញ។
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ សហការជាមួយមន្ទីរធនធានទឹករាជធានីភ្នំពេញ និងអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋាន អន្តរាគមន៍បូមទឹកសង្គ្រោះស្រូវវស្សាដែលជួបប្រទះគ្រោះរាំងស្ងួត នៅក្នុងសង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ ។
- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម និងការិយាល័យផែនការ គណនេយ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការចងក្រងស្ថិតិកសិកម្មលម្អិតតាមតំបន់ ។
- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម ការិយាល័យផ្សព្វផ្សាយកសិកម្ម និងការិយាល័យគ្រឿងយន្តកសិកម្ម សហការជាមួយអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋាន ចុះផ្សព្វផ្សាយ ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការងារបង្កបង្កើនផលស្រូវ ដំណាំរដូវប្រាំង និងរដូវវស្សាជូនប្រជាកសិករ និងចុះពិនិត្យផលប៉ះពាល់លើដំណាំនិងស្រូវវស្សាដោយគ្រោះរាំងស្ងួត នៅក្នុងសង្កាត់ប្រទះឡាង ខណ្ឌកំបូល។
- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម សហការជាមួយមន្ត្រីអគ្គនាយកដ្ឋានកសិកម្ម ចុះពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ នៅក្នុងរាជធានីភ្នំពេញ ។
- ការិយាល័យផ្សព្វផ្សាយកសិកម្មបានចុះណែនាំ និងចែករំលែកបទពិសោធន៍នៃការដាំដំណាំបន្លែរដូវវស្សានៅភូមិចំបក់មាស សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងបានចុះណែនាំ និងចែករំលែកបទពិសោធន៍ការដាំដុះដំណាំស្រូវដល់កសិករនៅសង្កាត់ទៀន ខណ្ឌដង្កោ និងដំណាំបន្លែ នៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

- ការិយាល័យផ្សព្វផ្សាយកសិកម្ម និងការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម សហការណ៍ជាមួយរដ្ឋបាលរាជធានីភ្នំពេញចុះបើកវគ្គបណ្តុះបណ្តាលស្តីពីការដាំដុះបន្លែសុវត្ថិភាពនៅអង្គការដើម្បីភាពញញឹមនៃកុមារ(PSE) រាជធានីភ្នំពេញក្រោមការផ្តួចផ្តើមរបស់លោកជំទាវ ជា ស៊ីណា ប្រធានក្រុមប្រឹក្សាសមាគមកាយឬទ្ធិកម្ពុជា សាខារាជធានីភ្នំពេញ ដែលមានសិស្សានុសិស្សចូលរួមចំនួន២៥នាក់។
- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម ការិយាល័យផ្សព្វផ្សាយកសិកម្ម ចុះស្រង់ស្ថិតិបរិមាណបន្លែនាំចូលក្នុងរាជធានីភ្នំពេញ ប្រភពនាំចូល និងបរិមាណចែកចាយទៅតាមបណ្តាខេត្ត នៅផ្សារដើមគរ ផ្សារនាគមាស ផ្សារទួលស្វាយព្រៃ ផ្សារច្បារអំពៅ និងផ្សារជម្ពូវ័ន្ត រាជធានីភ្នំពេញ ។
- ការិយាល័យគ្រឿងយន្តកសិកម្ម ចុះប្រមូលទិន្នន័យអាកាសយានគ្មានមនុស្សបើក(ដ្រូន) នៅតាមទីតាំងលក់
- គ្រឿងយន្ត និងឧបករណ៍កសិកម្ម និងណែនាំម្ចាស់អាជីវកម្មទៅធ្វើស្វ័យប្រកាសជាមួយអាជ្ញាធរមូលដ្ឋាន ។
- ការិយាល័យផលិតកម្ម និងបសុព្យាបាលចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់ក្រោមជាតិ ស្តីពីការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព្រឹត្តិការណ៍ដោយប្រើប្រាស់ឧបករណ៍៧-១-៧ សម្រាប់ព្រឹត្តិការណ៍សុខភាពសាធារណៈដល់មន្ត្រីក្រុមឆ្លើយតបបន្ទាន់ និងចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ស្តី ការត្រៀមខ្លួនសម្រាប់ការឆ្លើយតបការផ្ទុះឡើងនៃជំងឺឈាមខ្មៅ និងចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "QGIS Animal for Veterinary Officers Responsible for Animal Disease Surveillance and Outbreak Investigations and Response"។
- ការិយាល័យនីតិកម្មកសិកម្ម សហការជាមួយមន្ត្រីរដ្ឋបាលខណ្ឌ និងអាជ្ញាធរមូលដ្ឋាន ចុះធ្វើបច្ចុប្បន្នភាព និងត្រួតពិនិត្យទីតាំងអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្មនៅក្នុង ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌដូនពេញ ខណ្ឌបឹងកេងកង ខណ្ឌចំការមន ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌកំបូល រាជធានីភ្នំពេញ ។
- ការិយាល័យកសិឧស្សាហកម្ម ចូលរួមកិច្ចប្រជុំស្តីពីកម្មវិធីបណ្តាញទំនាក់ទំនងភាពជាដៃគូរធុរកិច្ចរវាងសហភាពអឺរ៉ុប-កម្ពុជា«ការនាំចេញ និងនវានុវត្តន៍កសិកម្ម» និងបានចូលរួមវគ្គបណ្តុះបណ្តាល " គ្រូបង្គោល (TOT) ស្តីពីខ្សែច្រវាក់តម្លៃដែលគិតគូរពីអាហារូបត្ថម្ភ" និងចូលរួមវគ្គបណ្តុះបណ្តាលស្តីពី"ការអនុវត្តអនាម័យល្អ ការវិភាគគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ (GHP/HACCP)"។
- ការិយាល័យកសិឧស្សាហកម្ម ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម និងការិយាល័យផ្សព្វផ្សាយ កសិកម្ម ចុះប្រមូលទិន្នន័យតួអង្គចម្បងៗក្នុងដំណាក់កាលប្រមូលទិញពីស្រែនៃខ្សែច្រវាក់តម្លៃស្រូវ អង្ករ នៅក្នុងរាជធានីភ្នំពេញ។
- ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម បានជួយសម្របសម្រួលគណៈកម្មការសហគមន៍រៀបចំការប្រជុំបូកសរុបការងារប្រចាំឆ្នាំចំនួន ៧សហគមន៍ និងចូលរួមមហាសន្និបាតប្រចាំឆ្នាំចំនួន ៣សហគមន៍ និងបានចូលរួមកិច្ចប្រជុំស្តីពីការបិទបញ្ជីប្រចាំខែ និងផ្សព្វផ្សាយយុទ្ធសាស្ត្រ ទីផ្សារដល់គណៈកម្មការសហគមន៍កសិកម្មព្រៃសរីកចម្រើន ស្ថិតនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ និងបានចូលរួមផ្សព្វផ្សាយស្តីពីការបោះឆ្នោតជ្រើសរើសបេក្ខភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មការត្រួតពិនិត្យសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និងបានចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញលើច្បាប់ ស្តីពីសហគមន៍កសិកម្ម ។
- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម ការិយាល័យផលិតកម្ម និងបសុព្យាបាល ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ខណ្ឌរដ្ឋបាលព្រៃឈើ ខណ្ឌរដ្ឋបាលជលផល ចុះប្រមូលទិន្នន័យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលធ្វើប្រតិបត្តិការលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងរាជធានីភ្នំពេញ។
- ខណ្ឌរដ្ឋបាលជលផលភ្នំពេញ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី បទបញ្ញត្តិសហភាពអឺរ៉ុប និងការអនុវត្តល្អក្នុងប្រព័ន្ធគ្រប់គ្រងម្ហូបអាហារ ការពិនិត្យប្រព័ន្ធត្រួតពិនិត្យផ្លូវការ និងលក្ខខណ្ឌតម្រូវសម្រាប់ការនាំចេញផល ផលិត ផលជលផលទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងលក្ខខណ្ឌតម្រូវនៃប្រព័ន្ធ ហាសិប(HACCP) សម្រាប់ផល ផលិតផលជលផល និងចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពី "ប្រកាសចំនួនប្រាំសម្រាប់គាំទ្រមាត្រា៩ នៃច្បាប់ថ្មីស្តីពីជលផល"។

## ខ. **ការខារចិញ្ចឹមសត្វ** (ឧបសម្ព័ន្ធ ៣)

### ខ.១. ស្ថិតិសត្វ

- គោ ៤ ០២១ ក្បាល (សាច់ ៣ ៦៧៧ក្បាល អូសទាញ ៣៤៤ក្បាល)

- ក្របី ១៤០ ក្បាល(សាច់ ១៣០ក្បាល)
- ជ្រូក ២ ០៤០ ក្បាល(បា ៥ក្បាល មេ ១៦៦ក្បាល កូន ៦៣៥ក្បាល សាច់ ១ ២៣៤ក្បាល)
- សេះ ៧ ក្បាល
- ពពែ ១៦៥ ក្បាល
- ចៀម ២០០ ក្បាល
- ទន្សាយ ១០០០ ក្បាល
- ឆ្កែ ៨០ ៣៥៥ ក្បាល
- ឆ្មា ១៨ ៩៤៦ ក្បាល
- មាន់ ១៨១ ២៣៨ ក្បាល (មាន់ពង ៦៩០០០ក្បាល មាន់សាច់ ១១២ ៧៣៨ក្បាល)
- ទា ៣៦ ៣៨៥ ក្បាល (ទាកាប ៣៥ ៥៧០ក្បាល និងទាកាប៉ា ៨១៥ក្បាល)
- ក្ងាន ២៣៥ ក្បាល

ការចិញ្ចឹមសត្វសរុបចំនួន **៣២៤ ៧៣២ក្បាល**។

## ខ.២. ស្ថានភាពសត្វឈឺ ការព្យាបាល និងសត្វស្លាប់ដោយជំងឺ

- ការព្យាបាលសត្វសរុប: **២ ៤៧៤ក្បាល** «គោ ១៣៨ក្បាល ជ្រូក ១២៩ក្បាល ឆ្កែ ១២៤២ក្បាល ឆ្មា ២៨០ក្បាល មាន់ ៦៨៥ក្បាល »
- សត្វស្លាប់សរុប: **៤៣៦ក្បាល**«ជ្រូក ១០ក្បាល ឆ្កែ ១៧ក្បាល មាន់ ៤០៩ក្បាល» ។

## ខ.៣.វិធានការការពារជំងឺឆ្លងសត្វ

- មន្ត្រីបសុពេទ្យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ចូលរួមសហការជាមួយមន្ត្រីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ចុះទប់ស្កាត់ និងអនុវត្តវិធានបសុពេទ្យ នៅទីតាំងអង្គការ Resource Development International នៅភូមិព្រែកធំ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលបន្ទាប់ពីបានបញ្ជូនវត្ថុវិភាគសត្វមាន់ចំនួន២ក្បាល យកទៅវិភាគនៅវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ជាលទ្ធផលវិភាគបង្ហាញថា មាន់ទាំង២ក្បាលខាងលើ មានវត្តមានវីរុសផ្តាសាយបក្សីក្នុងអនុក្រុម H5N1។ នៅទីតាំងខាងលើ មានចិញ្ចឹមសត្វមាន់តូចធំសរុបចំនួន ៤៣៤ក្បាលក្នុងនោះ សត្វមាន់បានស្លាប់ចំនួន ១៥៣ក្បាល (ចាប់ពីថ្ងៃទី១៨/០១/២៥ ដល់ថ្ងៃទី២៧/០១/២៥)និងនៅសល់សត្វមាន់នៅរស់ភាគច្រើនតូចៗចំនួន២៨១ក្បាល ។ តាមរយៈការពិភាក្សាជាមួយមន្ត្រីជំនាញ ខាងអង្គការបានយល់ព្រមសហការសម្លាប់សត្វមាន់ដែលនៅសល់ទាំងអស់។ វិធានការដែលបានអនុវត្តៈ ១-ណែនាំដល់ម្ចាស់សត្វមាន់ពីបច្ចេកទេស និងវិធានការការពារ-ទប់ស្កាត់ជំងឺឆ្លងពីសត្វទៅសត្វ និងឆ្លងពីសត្វទៅមនុស្ស ២-អនុវត្តវិធានជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគក្នុង និងជុំវិញទ្រុងសត្វ ៣-បានសម្លាប់ និងដុតកំទេចចោលសត្វមាន់រស់ដែលនៅសល់ទាំងអស់។ វិធានការអនុវត្តបន្ត គឺបន្តចុះតាមដាន ពិនិត្យ និងអនុវត្តវិធានជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគជាប្រចាំ ១សប្តាហ៍២ដង ក្នុងរយៈពេល១ខែពេញនៅក្នុង និងជុំវិញតំបន់ផ្ទុះជំងឺ សំដៅទប់ស្កាត់ការឆ្លងរាលដាលជំងឺផ្តាសាយបក្សីពីតំបន់ខាងលើទៅកាន់តំបន់ផ្សេងៗទៀត។

ការចុះពិនិត្យសុខភាពសត្វ និងផលិតផលសត្វ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ និងការធ្វើជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគត្រូវបានអនុវត្តជាក់ស្តែងនៅតាមកសិដ្ឋាន សត្តឃាតដ្ឋាន ទីតាំងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ នៅតាមទីផ្សារ ទីសាធារណៈ និងកន្លែងកែច្នៃផលិតផលសត្វ ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

- ការចាក់វ៉ាក់សាំងសត្វគោ ក្របី ពពែ ជ្រូក ឆ្កែ ឆ្មា មាន់ សរុបចំនួន **៧០៧៧ក្បាល** នៅក្នុងនោះៈ
  - ចាក់វ៉ាក់សាំងសត្វគោ សរុប : **១ ៣៦៣ក្បាល** «សារទឹក ១០៤០ក្បាល អុតក្តាម ២០៣ក្បាល ដុំពកស្បែក ១២០ក្បាល »
  - ចាក់វ៉ាក់សាំងសត្វក្របីសរុប : **១៦០ក្បាល** «សារទឹក ៨០ក្បាល អុតក្តាម ៨០ក្បាល »
  - ចាក់វ៉ាក់សាំងសត្វពពែសរុប : **៣៣៣ក្បាល** «សារទឹក ៣៣៣ក្បាល »
  - ចាក់វ៉ាក់សាំងសត្វជ្រូកសរុប : **១ ៣៦៧ក្បាល** «អុតក្តាម ១២៥ក្បាល ប៉េស្ត ២៨១ក្បាល អូហ្សេស្គី ៤១៥ក្បាល ជាតិដែក ៣២០ក្បាល រាគកូនជ្រូក ២២៦ក្បាល»

- ចាក់វ៉ាក់សាំងសត្វឆ្កែ ឆ្មា សរុប: **១ ៩៣៤ក្បាល** « ឆ្កែ ១៥៣៧ក្បាល ឆ្មា ៣៩៧ក្បាល»
- ចាក់វ៉ាក់សាំងសត្វមាន់ សរុប :**១ ៩២០ក្បាល**«អាសន្នរោគ ៤៩០ក្បាល ញូវកាស ១៤៣០ក្បាល »

- ការគ្រៀវសត្វឆ្កែ ឆ្មា សរុបចំនួន **២០ក្បាល** « ឆ្កែ ៧ក្បាល ឆ្មា ១៣ក្បាល»
- ធ្វើជីវសុវត្ថិភាពបាញ់ថ្នាំសម្លាប់មេរោគ សរុប : **១ ៣៧៨លើក**
  «ទីតាំងចិញ្ចឹមសត្វ ២៤០លើក សត្តឃាតដ្ឋាន ១០២០លើក ទីផ្សារ ១១២លើក ផ្លូវជាតិ ៦លើក»។

## ខ.៤. ការត្រួតពិនិត្យអនាម័យសាច់សត្វ នៅទីសត្តឃាតដ្ឋាន

- គោ **២៦០២៣ក្បាល** ទម្ងន់សាច់ស្អាត ២៧៣២៤១៥គ.ក្រ និងសាច់មិនស្អាត ២៧០គ.ក្រ
- ជ្រូក **២២៩៧៨១ក្បាល** ទម្ងន់សាច់ស្អាត ១៨៣៨២៤៨០គ.ក្រ និងសាច់មិនស្អាត ៣១៥គ.ក្រ
- មាន់ **៦១១៤២៩ក្បាល** គិតជាទម្ងន់សាច់ស្អាត ៧៣៣៧១៤,៨គ.ក្រ
- សាច់ និងផលិតផលសត្វទាំងអស់ត្រូវបានអនុវត្តតាមនីតិវិធីនៃការត្រួតពិនិត្យសត្វរស់មុនពេលពិឃាត ត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វក្រោយពេលពិឃាត និងអូសត្រាសម្គាល់ពីមន្ត្រីបសុពេទ្យនៅក្នុងសត្តឃាតដ្ឋាន មុនពេលបញ្ចេញទៅកន្លែងតាំងលក់នៅតាមទីផ្សារ សំដៅធានាបាននូវគុណភាពសុវត្ថិភាពសាច់ និងផលិតផលសត្វ ដើម្បីរួមចំណែករក្សាបាននូវសុខភាពសាធារណៈ និងសុវត្ថិភាពចំណីអាហារនៅក្នុងរាជធានីភ្នំពេញ។ សាច់មិនស្អាតចំនួន **៥៨៥គ.ក្រ**(សាច់ហើម ជាំ ដោយការប៉ះទង្គិចក្នុងពេលដឹកជញ្ជូន) ត្រូវបានដុតបំផ្លាញចោលមិនអនុញ្ញាតឱ្យធ្វើចរាចរចូលទីផ្សារឡើយ។

## ខ.៥. ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វនាំចូលរាជធានីភ្នំពេញ

- បរិមាណជ្រូក ក្នុងស្រុក សរុប: **២២៩៧៨១ក្បាល**
  - ក្រុមហ៊ុន «ស៊ីភី» : ៦៨៩៣៥ក្បាល
  - ក្រុមហ៊ុនម៉ុងឫទ្ធី : ៤៥៩៥៦ក្បាល
  - ក្រុមហ៊ុនបេតាហ្គ្រោ : ២២៩៧៨ក្បាល
  - លក្ខណៈគ្រួសារ : ១១៤៨៩ក្បាល
  - កសិដ្ឋានក្នុងស្រុក : ៨០៤២៣ក្បាល
- គោ : **២៦០២៣ក្បាល**
- មាន់ : **៦១១៤២៩ក្បាល**

## ខ.៦. ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វនាំចេញ " គ្មាន

## ខ.៧. ទីតាំងលក់ជ្រូកខ្វៃ កន្លែងខ្វៃជ្រូក លក់សាច់ត្រជាក់ ក្នុងរាជធានីភ្នំពេញ

- ខណ្ឌ៧មករា ទីតាំងខ្វៃជ្រូក ០៣កន្លែង លក់ជ្រូកខ្វៃ ១១កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌបឹងកេងកង ទីតាំងខ្វៃជ្រូក០២កន្លែង
- ខណ្ឌទួលគោក ទីតាំងខ្វៃជ្រូក ០៤កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌច្បារអំពៅ ទីតាំងខ្វៃជ្រូក ០១កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌមានជ័យ ទីតាំងខ្វៃជ្រូក និងលក់ជ្រូកខ្វៃ ០៧កន្លែង
- ខណ្ឌជ្រោយចង្វារ ទីតាំងលក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌឫស្សីកែវ ទីតាំងខ្វៃជ្រូក ០៦កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌព្រែកព្នៅ ទីតាំងលក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌសែនសុខ ទីតាំងខ្វៃជ្រូក ០១កន្លែង លក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌដង្កោ ទីតាំងខ្វៃជ្រូក ០១កន្លែង លក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌពោធិ៍សែនជ័យ ទីតាំងខ្វៃជ្រូក ០៤កន្លែង
- ខណ្ឌកំបូល ទីតាំងខ្វៃជ្រូក០២កន្លែង

## ខ.៨.ការងារបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនសត្វ ផលិតផលសត្វ

ក.បានចូលរួមសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ធ្វើការឃាត់ចាប់បទល្មើស ចំនួន៤ករណី និងដុតកម្ទេចចោលវត្ថុតាងបទល្មើសដែលបានឃាត់ចាប់នាពេលកន្លងមក ៣ករណី នៅទីលានចាក់សំរាម ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយមានចូលរួមពីតំណាងសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា និងសម្របសម្រួលនីតិវិធីពីឯកឧត្តមព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ៖

- ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៥ បានឃាត់ចាប់រថយន្ត១គ្រឿងម៉ាក MITSUBISHI FUSO ស្លាកលេខ ភ្នំពេញ 3F-1317 ដឹកមាន់រស់ចំនួន៣៦៤០ក្បាលស្មើនឹង៥២០ស្រកា ដោយមិនមានលិខិតអនុញ្ញាត នៅលើដងផ្លូវជាតិលេខ៥ ត្រង់ចំណុចក្បែររង្វង់មូល គល់ស្ពានព្រែកព្នៅ ខណ្ឌព្រែកព្នៅ ។
- ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៥ បានឃាត់ចាប់រថយន្ត១គ្រឿងម៉ាកសាំយ៉ុង ស្លាកលេខ ភ្នំពេញ 2AE 7704 ដឹកពងមាន់ចំនួន១៥០ដុំ ស្មើនឹង៤៥០០០គ្រាប់ ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវស៊ីជីនពីង ភូមិព្រះធាតុ សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។
- ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥ បានឃាត់ចាប់រថយន្ត១គ្រឿងម៉ាកសាំយ៉ុង ស្លាកលេខ ភ្នំពេញ 2L 9476 ដឹកពងមាន់ចំនួន៨០ដុំ ស្មើនឹង២៤០០០គ្រាប់ ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវជាតិលេខ១ មុខវត្តចំប៉ា សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

  រាល់វត្ថុតាងនៃបទល្មើសបានប្រគល់ជូន អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីរក្សាទុក និងអនុវត្តតាមនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។
- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ បានចុះបង្ក្រាបសកម្មភាពល្មើសច្បាប់នៅទីតាំងប្រមូលផ្តុំ និងពិឃាតសត្វជ្រូកខុសច្បាប់ របស់ឈ្មោះ ស៊ុន គឹមសៀ នៅសង្កាត់បឹងទំពន់២ ខណ្ឌមានជ័យ ដោយទទួលបានលទ្ធផលដូចខាងក្រោម :

  \+ ឃាត់ចាប់សត្វជ្រូកចំនួន១៧៦ក្បាល(ងាប់៥ក្បាល) បញ្ជូនទៅស្ថានីយចត្តាឡីស័ក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីយកសំណាកទៅពិសោធន៍ស្វែងរកមេរោគជំងឺឆ្លងសត្វ។

  \+ ឃាត់ចាប់ជ្រូកបង្អកចំនួន៤ទូ ប្រមាណ៨០ក្បាល ប្រគល់ជូនអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ(ក.ប.ប.)នៃក្រសួងពាណិជ្ជកម្ម តាមបញ្ជារបស់តំណាងអយ្យការ ដើម្បីពិសោធន៍រកសារធាតុគីមីខុសច្បាប់ និងកំពុងរៀបចំចងក្រងសំណុំរឿងនៃបទល្មើស តាមនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។
- ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ បានរៀបចំពិធីដុតកម្ទេចវត្ថុតាងល្មើសច្បាប់ជ្រូកមានមេរោគប៉េស្តអាហ្វ្រិក African Swine Fever (ASF) ចំនួន១៧៦ក្បាល ដែលបានចុះបង្ក្រាប និងឃាត់ចាប់ នៅទីតាំងអាជីវកម្មប្រមូលផ្តុំ និងពិឃាតសត្វជ្រូក គ្មានលិខិតអនុញ្ញាត នៅសង្កាត់បឹងទំពន់២ ខណ្ឌមានជ័យ កាលពីថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៥ ។
- ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២៥ បានធ្វើការដុតកម្ទេចចោលសាច់មាន់ និងស្លាបមាន់បង្អកខូចគុណភាព ចំនួន១៥០០គីឡូក្រាម ។
- ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០២៥ បានធ្វើការដុតកម្ទេចចោល សាច់បង្អក (គូទមាន់ ឆ្អឹងជំនីជ្រូក សរសៃគោ ខ្លាញ់ជ្រូក ស្លាបមាន់ សាច់មាន់កិន សាច់គោ សាច់ជ្រូក) ខូចគុណភាពនិង ហួសសុពលភាព ចំនួន ២៦១៦០គីឡូក្រាម ។

ខ. ក្រុមការងារបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនសត្វ ផលិតផលសត្វនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ បានចុះស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសសន្និធិ និងដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វ បានចំនួន០២ករណី :

- ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៥ បានធ្វើការចាប់ឃាត់រថយន្ត១គ្រឿងម៉ាកសាំយ៉ុង ពណ៌ទឹកប្រាក់ ស្លាកលេខ ព្រៃវែង 2A-1169 ដឹកកូនជ្រូកកណ្តុររស់ចំនួន ១០៥ក្បាល ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវ៦០ម៉ែត្រ ក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។
- ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ បានធ្វើការចាប់សត្វជ្រូករស់(កូនជ្រូកកណ្តុរ)ចំនួន ៨៧ក្បាល នាំចូលពីប្រទេសវៀតណាម ដោយគ្មានលិខិតអនុញ្ញាត នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

  រាល់វត្ថុតាងនៃបទល្មើសបានយកទៅរក្សាទុកនៅចត្តាឡីស័កសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីអនុវត្តតាមនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។

**គ. ការងារនេសាទ** (ឧបសម្ព័ន្ធ ៤)

**គ.១.អាជីវកម្មនេសាទ**

- ស្ថិតិផលនេសាទៈ

ផលត្រីចាប់បានក្នុងនព្វមាស ឆ្នាំ២០២៥ សរុបចំនួន **៩៩៨តោន**

  - ឧបករណ៍ឧស្សាហកម្ម (ដាយត្រី) ៤៨៥តោន
  - នេសាទគ្រួសារក្នុងដែននេសាទ ៤៩០តោន
  - នេសាទគ្រួសារតាមវាលស្រែ ២៣តោន

ក្នុងនព្វមាសឆ្នាំ២០២៥ ការនេសាទមានសកម្មភាពប្រហាក់ប្រហែលឆ្នាំកន្លងទៅ ទាំងការនេសាទឧស្សាហកម្ម(ដាយត្រី) និងការនេសាទជាលក្ខណៈគ្រួសារក្នុងដែននេសាទ ប៉ុន្តែការប្រមូលផលត្រីកើនឡើងជិតពីរដងប្រៀបធៀបនព្វមាស ឆ្នាំ២០២៤។ ឧបករណ៍នេសាទឧស្សាហកម្ម(ដាយត្រី) និងនេសាទជាលក្ខណៈគ្រួសារ រួមមាន មង នាម លប ចៃវ៉ា ថ្នង សំណាញ់ សន្ទូច។ល។

**គ.២.ស្ថិតិវារីវប្បកម្ម**

- ត្រីចិញ្ចឹម សរុបចំនួន **១៥ ៨៦៨តោន**
  - ចិញ្ចឹមតាមស្រះ ១៤ ៥៦៥តោន
  - ចិញ្ចឹមតាមបៃ ១ ៣០៣តោន
- កង្កែបចិញ្ចឹម សរុបចំនួន **៣,១០តោន**
- ក្រពើចិញ្ចឹម សរុបចំនួន **២០០ក្បាល**
  - ក្រពើមេ ១៧០ក្បាល
  - ក្រពើបា ៣០ក្បាល

  ក្នុងនព្វមាសឆ្នាំ២០២៥នេះ ក្រពើចំនួន ៤៨៥ក្បាល ត្រូវបានលក់ចេញ ក្នុងនោះមាន ក្រពើមេ ២០០ក្បាល ក្រពើបា ១៣០ក្បាល និងក្រពើជំទង់ ១៥៥ក្បាល។
- ប្រជាជនយកចិត្តទុកដាក់ពង្រីកមុខរបរចិញ្ចឹមជីវិតតាមរយៈការធ្វើវារីវប្បកម្ម ការប្រមូលផលមានការកើនឡើងប្រមាណ៥០០០តោនប្រៀបធៀបនព្វមាសឆ្នាំ២០២៤។ ប្រភេទត្រីដែលដាក់ចិញ្ចឹមរួមមានត្រីប្រាទីឡាព្យ៉ា កាបស កាបសាមញ្ញ ឆ្តិន ពោ កែ ប្រាខ្មៅ និងកង្កែប។

**គ.៣.ការកែច្នៃផលនេសាទ**

- ការកែច្នៃផលនេសាទ សរុបចំនួន **២ ០២៦តោន** «ត្រីងៀត ប្រហុក ផ្អក ម៉ាំ ត្រីឆ្អើរ ត្រីប្រឡាក់ ប្រហិត .......»
- ផលិតទឹកត្រី សរុបចំនួន **៣ ០៥៨ ២៤១លីត្រ** ។
- ការចេញលិខិតអនុញ្ញាតឱ្យបង្កើតទីតាំងទិញ លក់សន្និធិ ឬកន្លែងកែច្នៃផល ផលិតផលជលផលក្នុងនព្វមាសឆ្នាំ២០២៥ សរុបចំនួន **៩៨ច្បាប់**។

**គ.៤.ការនាំចូលផលនេសាទ**

- ការនាំចូលផលនេសាទ សរុបចំនួន **៣៥ ៣៦០តោន**
  - ផលនេសាទទឹកសាប ចំនួន ៣០ ៩៣៨តោន
  - ផលនេសាទសមុទ្រ ចំនួន ៤ ៤២២តោន។

**គ.៥.ផលនេសាទនាំចូលពីបណ្តាខេត្ត**

- ផលនេសាទនាំចូលពីបណ្តាខេត្ត សរុបចំនួន **១៧ ៨៨៧តោន**
  - ផលនេសាទទឹកសាប ចំនួន ១១ ០០០តោន
  - ផលនេសាទសមុទ្រ ចំនួន ៦ ៨៨៧តោន។

**គ.៦.ការងារបង្ក្រាបបទល្មើសនេសាទ**

- ក្នុងនព្វមាស ឆ្នាំ២០២៥ បានកសាងកំណត់ហេតុបទល្មើសបំផ្លាញចោលសរុបចំនួន **២១ករណី**។ វត្ថុតាងបំផ្លាញចោលរួមមានៈ លបកន្ទុយកណ្តុរ ៣៧គ្រឿង លូស្បៃមុង ១គ្រឿង របាំងស្បៃមុង ១៥ម៉ែត្រ បង្គោល ២៧ដើម មែកសម្រាស់ ៦០ដើម កានប្រេងចំណុះ៣០លីត្រចំនួន១២ និងលែងកូនត្រីចម្រុះ ២៨គីឡូក្រាម។

**ឃ. ការងារព្រៃឈើ** (ឧបសម្ព័ន្ធ ៥)

**ឃ.១.ការបណ្តុះ ចែកចាយ និងដាំកូនឈើ៖**

- ការបណ្តុះកូនឈើ សរុបចំនួន **៦ ៥០០ដើម**
- ការចែកចាយកូនឈើ សរុបចំនួន **២ ២៨៧ដើម**
- ការដាំកូនឈើ សរុបចំនួន **២៨៥ដើម។**

កូនឈើនៅសល់ក្នុងថ្នាលសរុបចំនួន ៣០ ៣១៥ដើម ក្នុងនោះ កូនឈើរយៈពេលខ្លី ៨០០ដើម កូនឈើរយៈពេលវែង ២៧ ៥៦៥ដើម និងកូនឈើហូបផ្លែ ១៩៥០ដើម។

**ឃ.២.រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ**

- បានចេញលិខិតអនុញ្ញាតបន្តសុពលភាពសរុប៖
  - រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ ចំនួន **៣៣កន្លែង។**
  - រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច **២៣កន្លែង។**
- មានរោងម៉ាស៊ីនអារឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទមធ្យមចំនួន **៣កន្លែង** ។
- មានរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ចំនួន **២កន្លែង** គឺក្រុមហ៊ុន អៀង ប៊ុនថន និងក្រុមហ៊ុន កែវ ស៊ីម ។

**ឃ.៣.ការដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូល ចេញ**

- ការដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានមាន ឈើអារចម្រុះប្រភេទសរុបចំនួន **៣៦៨៣ម៣៨១៥** កូនឈើចំនួន **៥៨៥ដើម** និងអុសចំនួន **៥២៨ស្ទែរ។**

**ឃ.៤.ការបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ (គ្មាន)**

**ង. ការងារគណនេយ្យ ហិរញ្ញវត្ថុ** (ឧបសម្ព័ន្ធ ៦)

**ង.១.ចំណូល :**

- ចំណូលសរុបចំនួន **៦០១ ២៤១ ០០០រៀល** ក្នុងនោះ ៖
  - ចំនួន ៤៥០ ៦៤១ ០០០រៀល ជាកម្រៃសេវាពីផ្នែកផលិតកម្ម និងបសុព្យាបាល (បង់ចូលថវិកាជាតិ តាមរយៈអង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ)។
  - ចំនួន ៩៧ ៦០០ ០០០រៀល ជាកម្រៃសេវាពីផ្នែកជលផល(ឈ្នួលដាយត្រី) (បង់ចូលថវិកាជាតិ តាមរយៈរដ្ឋបាលរាជធានីភ្នំពេញ)។
  - ចំនួន ៥៣ ០០០ ០០០រៀល ជាកម្រៃមកពីសេវាសាធារណៈចេញលិខិតអនុញ្ញាតរបស់ខណ្ឌរដ្ឋបាលព្រៃឈើ (បង់ចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ)។

**ង.២.ចំណាយ :**

- ចំណាយ សរុបចំនួន **២ ៩៦៨ ៧៣៦ ៤១០រៀល** ក្នុងនោះ៖
  - ចំនួន ៣២ ៩៩៥ ៦០០រៀល ជាសេវាកម្ម (ជំពូក៦០)
  - ចំនួន ២៩៧ ៦៨៧ ៧៤០រៀល ជាការទិញ (ជំពូក៦១)
  - ចំនួន ១៩ ៩៩៦ ៩០០រៀល ជាអត្ថប្រយោជន៍សង្គម (ជំពូក៦២)
  - ចំនួន ១ ០០០ ០០០រៀល ចំណាយផ្សេងៗ (ជំពូក៦៣)
  - ចំនួន ២ ៥២២ ៩០១ ៥៣០រៀល ជាបៀវត្សមន្ត្រីរាជការ (ជំពូក៦៤)
  - ចំនួន ៥៧ ៦៨៩ ០០០រៀល ជាប្រាក់កម្រៃបុគ្គលិកជាប់កិច្ចសន្យា (ជំពូក៦៤)
  - ចំនួន ៨ ១០០ ០០០រៀល ជាប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំប្រពៃណីជាតិ (ជំពូក៦៤)
  - ចំនួន ៨ ០៥០ ០០០រៀល ជាប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ (ជំពូក៦៤)
  - ចំនួន ២០ ៣២៤ ៦៤០រៀល ជាប្រាក់ឧបត្ថម្ភមន្ត្រីចូលនិវត្តន៍ (ជំពូក៦៤)។

## ច. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យ អង្គភាពក្រោមឱវាទ (ឧបសម្ព័ន្ធ ៧)

| ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យ និង អង្គភាពក្រោមឱវាទ | កិច្ចប្រជុំ សិក្ខាសាលា សន្និបាត.... | ពិធីផ្សេងៗ | សរុប |
|---|---|---|---|
| ថ្នាក់ដឹកនាំមន្ទីរ | ១២៥ | ១៣ | ១៣៨ |
| ខណ្ឌរដ្ឋបាលព្រៃឈើ | ១២ | ១១ | ២៣ |
| ខណ្ឌរដ្ឋបាលជលផល | ២១ | ២ | ២៣ |
| ការិ.រដ្ឋបាល បុគ្គលិក | ១៨ | ២ | ២០ |
| ការិ.ផែនការ គណនេយ្យ | ៤១ | ១ | ៤២ |
| ការិ.ផលិតកម្ម និងបសុព្យាបាល | ១៤ | - | ១៤ |
| ការិ.ក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម | ១១ | ១ | ១២ |
| ការិ.គ្រឿងយន្តកសិកម្ម | ២ | - | ២ |
| ការិ.ផ្សព្វផ្សាយកសិកម្ម | ៤ | ១ | ៥ |
| ការិ.អភិវឌ្ឍន៍សហគមន៍កសិកម្ម | ៥ | ១ | ៦ |
| ការិ.កសិឧស្សាហកម្ម | ៨ | ១ | ៩ |
| ការិ.នីតិកម្មកសិកម្ម | ៤ | ១ | ៥ |
| ការិ.កៅស៊ូ | ២ | ១ | ៣ |

## ឆ. បញ្ហាប្រឈម និងដំណោះស្រាយ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| **១. ការងារបង្កបង្កើនផល** | | |
| | ការយល់ដឹងរបស់ប្រជាកសិករនៅមានកម្រិត ក្នុងផលិតកម្មកសិកម្ម និងការបង្កើនទិន្នផលស្រូវ និងដំណាំ។ | ចាត់មន្ត្រីជំនាញចុះផ្សព្វផ្សាយណែនាំបច្ចេកទេសសាមញ្ញៗ ដែលកសិករអាចយកទៅអនុវត្តបាន ដើម្បីជួយកសិករពង្រឹងសមត្ថភាព បច្ចេកទេស សំដៅបង្កើនទិន្នផលស្រូវ និងដំណាំឲ្យទទួលបានផលខ្ពស់ មានដូចជា៖<br>១.ករណីដីស្រែប្រភេទដីអាស៊ីត(PHតិច)ត្រូវបាចកំបោរស ឬផេះ ដើម្បីបង្កើន(PH) ឲ្យបាន ៦,៥-៧,៥<br>២.ត្រូវភ្ជួរលុបចំបើង និងគល់ជញ្ជ្រាំងចូលក្នុងដី បន្ទាប់ពីប្រមូលផលស្រូវរួច ដើម្បីបង្កើនសារធាតុចិញ្ចឹម NPK<br>៣.ការរៀបចំដី ត្រូវពង្រាបដីឲ្យបានរាបស្មើ ងាយស្រួល ក្នុងការគ្រប់គ្រងទឹក និងសារធាតុចិញ្ចឹមបានស្មើគ្នា<br>៤.មុនសាប ស្ទូង និងព្រោះ ត្រូវប្រើប្រាស់ជីសរីរាង្គទ្រាប់បាត<br>៥.ប្រើប្រាស់គ្រាប់ពូជស្រូវសុទ្ធល្អ<br>៦.ចុះស្រែជាប្រចាំ ដើម្បីគ្រប់គ្រងទឹក សត្វល្អិត ជំងឺ និងគ្រប់គ្រងសារធាតុចិញ្ចឹម<br>៧.ការទុកដាក់គ្រាប់ពូជស្រូវ ត្រូវច្រូតកាត់ក្នុងសំណើម២១%-២៥% ហាលឲ្យស្ងួតល្អរហូតត្រឹមសំណើម១៣%-១៤%។ |
| **២. ការងារចិញ្ចឹមសត្វ** | | |
| | ដោយសារកំណើនប្រជាពលរដ្ឋមករស់នៅប្រកបរបរ ទទួលទាននៅរាជធានីភ្នំពេញកាន់តែច្រើនធ្វើឲ្យសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតឲ្យបង្កើតពីពេលមុនដែលស្ថិតនៅឆ្ងាយពីទីប្រជុំជន និងទីសាធារណៈនានាបានប្រែក្លាយជាមានប្រជាពលរដ្ឋមករស់នៅជុំវិញយ៉ាងកុះករ ធ្វើឲ្យមានការរំខាន និងប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្បែរខាង ។ | -ចុះពិនិត្យការអនុវត្តវិធានបសុពេទ្យ បទដ្ឋានអនាម័យ និងបច្ចេកទេសនៅតាមសត្តឃាតដ្ឋានដែលមានលិខិតអនុញ្ញាតរួចពីមុនសំដៅជំរុញការពង្រឹងការអនុវត្តច្បាប់ ដើម្បីកាត់បន្ថយការប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្បែរខាង<br>-សត្តឃាតដ្ឋានដែលនឹងត្រូវស្នើសុំបង្កើតថ្មីអាចពិនិត្យ និងសម្រេចផ្តល់ជូនបានលុះត្រាមានតែទីតាំងនៅជាយរាជធានីឆ្ងាយពីទីប្រជុំជន និងជាតម្រូវការចាំបាច់តែប៉ុណ្ណោះ។ |

## ៥. ផែនការប្រចាំខែតុលា ឆ្នាំ២០២៥

| ល.រ | សកម្មភាពជាអាទិភាព | គុណភ |
|---|---|---|
| | **ក.ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម** | |
| ១ | ជំរុញការប្រមូលផលស្រូវ និងដំណាំរដូវវស្សា និងត្រៀមការដាំដុះរដូវប្រាំងឆ្នាំ២០២៥-២០២៦។ | ✓ |
| ២ | ចុះផ្សព្វផ្សាយណែនាំបច្ចេកទេសសមស្របដល់កសិករ ដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំផ្សេងៗ។ | ✓ |
| ៣ | សហការជាមួយការិយាល័យជំនាញ និងមន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ ដើម្បីរៀបចំផែនការត្រៀមសម្រាប់អន្តរាគមន៍ក្នុងករណីមានគ្រោះធម្មជាតិកើតឡើង។ | ✓ |
| | **ខ.ការិយាល័យផលិតកម្ម និងបសុព្យាបាល** | |
| ៤ | បង្កើនការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ។ | ✓ |
| ៥ | ជំរុញការងារចិញ្ចឹមសត្វ ជាលក្ខណៈគ្រួសារ និងពាក់កណ្ដាលឧស្សាហកម្ម។ | ✓ |
| ៦ | បង្កើនការត្រួតពិនិត្យការស្តុក ការដឹកជញ្ជូនចលនាសត្វរស់ និងផលិតផលមានដើមកំណើតពីសត្វ ចេញ ចូលរាជធានីភ្នំពេញ និងមានវិធានការទប់ស្កាត់ជំងឺឆ្លងសត្វ។ | ✓ |
| ៧ | កែលម្អរចនាសម្ព័ន្ធសត្តឃាតដ្ឋានឲ្យមានអនាម័យសមស្របតាមលក្ខណៈបច្ចេកទេស។ | ✓ |
| ៨ | ជំរុញម្ចាស់សត្តឃាតដ្ឋានដែលមិនទាន់បានបំពេញបែបបទលិខិតស្នាមស្នើសុំបង្កើតសត្តឃាតដ្ឋានតាមខ្លឹមសារនៃអនុក្រឹត្យលេខ ១០៨ អនក្រ.បក ឲ្យបានទាន់ពេលវេលា។ | ✓ |
| ៩ | ត្រៀមថ្នាំសម្រាប់ព្យាបាលសត្វក្នុងករណីមានគ្រោះធម្មជាតិ ឬជំងឺឆ្លងសត្វកើតឡើង។ | ✓ |
| ១០ | ត្រួតពិនិត្យទីតាំងសាច់ត្រជាក់នៅតាមបណ្ដាខណ្ឌ។ | ✓ |
| | **គ.ខណ្ឌរដ្ឋបាលជលផល** | |
| ១១ | ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ។ | ✓ |
| ១២ | តាមដាន និងត្រួតពិនិត្យការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទ។ | ✓ |
| ១៣ | ជំរុញការធ្វើវារីវប្បកម្មឲ្យបានទូលំទូលាយ ពិសេសតំបន់ជាយរាជធានីភ្នំពេញ។ | ✓ |
| | **ឃ.ខណ្ឌរដ្ឋបាលព្រៃឈើ** | |
| ១៤ | ចុះពិនិត្យ ថែទាំ ដាំជួសដើមឈើដែលបានដាំរួចនៅតាមដងផ្លូវក្នុងរាជធានី។ | ✓ |
| ១៥ | ថែទាំ និងចែកចាយកូនឈើសម្រាប់ដាំក្នុងរាជធានីភ្នំពេញ។ | ✓ |
| ១៦ | ចុះផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានផ្សេងៗ។ | ✓ |
| ១៧ | ចុះត្រួតពិនិត្យ និងកាត់ស្តុកតាមរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ។ | ✓ |
| ១៨ | ចុះត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ ចូល ចេញ និងឆ្លងកាត់។ | ✓ |
| ១៩ | ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ។ | ✓ |
| | **ង.ការិយាល័យផ្សេងៗ** | |
| ២០ | ជំរុញការអនុវត្ត និងណែនាំបច្ចេកទេសបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ | ✓ |
| ២១ | បន្តចុះពិនិត្យលើការប្រើប្រាស់ឧបករណ៍កសិកម្មក្នុងការបង្កបង្កើនផលស្រូវ។ | ✓ |
| ២២ | ចុះធ្វើបច្ចុប្បន្នភាពទីតាំងលក់គ្រឿងយន្តកសិកម្មក្នុងរាជធានីភ្នំពេញ។ | ✓ |
| ២៣ | បន្តចូលរួមសម្របសម្រួលពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍កសិកម្ម។ | ✓ |
| ២៤ | ចុះផ្សព្វផ្សាយច្បាប់សហគមន៍កសិកម្ម និងពង្រឹងការងារគ្រប់គ្រងសហគមន៍កសិកម្ម។ | ✓ |
| ២៥ | ចុះធ្វើបច្ចុប្បន្នភាពទីតាំងកែច្នៃផលិតផលកសិកម្ម។ | ✓ |
| ២៦ | ចុះផ្សព្វផ្សាយបច្ចេកទេសកែច្នៃផលិតផលកសិកម្មក្រោយពេលប្រមូលផលដល់កសិករ។ | ✓ |
| ២៧ | ចុះសួរតម្លៃផលិតផលកសិ-ឧស្សាហកម្មនៅតាមផ្សារធំៗក្នុងរាជធានី។ | ✓ |
| ២៨ | ចុះធ្វើបច្ចុប្បន្នភាព និងត្រួតពិនិត្យទីតាំងលក់ជីកសិកម្ម និងថ្នាំកសិកម្មតាមខណ្ឌក្នុងរាជធានី។ | ✓ |
| ២៩ | បន្តទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងស្ថាប័នពាក់ព័ន្ធក្នុងការបំពេញការងារ។ | ✓ |
| ៣០ | ប្រមូលទិន្នន័យកៅស៊ូ និងតម្លៃកៅស៊ូ។ | ✓ |

ថ្ងៃ ចន្ទ ៧កើត ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២៥

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ**

**ញៀម នារារិទ្ធ**